**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ០៤ ខ ចុះថ្ងៃទី ០៨
ខែ កុម្ភៈ ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ៤៨៤ ចុះថ្ងៃទី ២៨
ខែ ធ្នូ ឆ្នាំ ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក[redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៤៨៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង :

-ប្តឹងសុំលែងលះប្តី

-ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន

-ប្តឹងសុំប្រាក់អាហារកិច្ចចិញ្ចឹមកូន

រវាងដើមចោទឈ្មោះ រ ៖ទ ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់បន្លែ ទីលំនៅ៧ភូមិទី១ ឃុំចុងឃ្នាស ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ម រ (ស) ម្តាយឈ្មោះ ឈ ស (រ) ប្តីឈ្មោះ ស ស មានកូន ០៥នាក់ ។

និងចុងចម្លើយឈ្មោះ ស ស ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មកររើសែង ទីលំនៅ៧ភូមិទី១ ឃុំចុងឃ្នាស ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ព ស (ស) ម្តាយឈ្មោះ ជ ម (ស) ប្រពន្ធឈ្មោះ រ ៖ទ មានកូន ០៥នាក់ ។

**ដំណើររឿងមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដើមចោទឈ្មោះ រ ៖ទ បានប្តឹងសុំលែងលះចុងចម្លើយឈ្មោះ ស ស ដោយសំអាងហេតុថា បានរៀបការត្រឹមត្រូវតាមច្បាប់ជាមួយចុងចម្លើយតាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៦
ដោយពុំមានគូភាគីណាមួយចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប,ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា
[redacted]

០៥នាក់ ។ តែការរស់នៅមិនចុះសំរុងនឹងគ្នា ប្ដីរបស់ខ្លួនលេងល្បែងស៊ីសងផឹកស្រាស្រវឹងពាលា មិនផ្ដល់ប្រាក់អោយទេ និង ទៅមានស្រីថ្មីទៀតធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្ដី ប្រពន្ធតទៅទៀតបានឡើយ ។

– **នាពេលសវនាការ**

ដើមចោទឈ្មោះ រ ៖ទ បានឆ្លើយថា ខ្លួនប្ដឹងសុំលែងលះចុងចម្លើយ ដោយមូលហេតុខ្លួនបានរៀបការត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន ០៥នាក់ ។ តែការរស់នៅមិនចុះសំរុងនឹងគ្នាសោះ ប្ដីរបស់ខ្លួនដើរលេងល្បែងស៊ីសង និង ទៅមានស្រីថ្មីទៀតបានចុះចោលខ្លួន និង កូនរយះពេល ០៥ខែហើយពុំដែលជួយផ្គត់ផ្គង់ចិញ្ចឹមកូនសោះ ទុកអោយខ្លួនទទួលបន្ទុកតែម្នាក់ឯង ។

ចំពោះកូន ០៥នាក់ គឺកូនទី១ ឈ្មោះ ស ផល ភេទស្រី អាយុ ១០ឆ្នាំ, កូនទី២ ឈ្មោះ ស ផលឡ ភេទស្រី អាយុ ០៩ឆ្នាំ, កូនទី៣ ឈ្មោះ ស មរទ ភេទប្រុស អាយុ ០៨ឆ្នាំ, កូនទី៤ ឈ្មោះ ស សណ ភេទស្រី អាយុ ០៦ឆ្នាំ និង កូនទី៥ ឈ្មោះ ស ផល ភេទស្រី អាយុ ០៣ឆ្នាំ ខ្លួនសុំសិទ្ធិគ្រប់គ្រងកូនទាំងអស់ និង សុំឱ្យចុងចម្លើយជួយបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្ដាច់ចំនួន ១.២០០.០០០៛០០ "មួយលានពីរសែនរៀល" ប៉ុណ្ណោះដើម្បីជាដើមទុនរកស៊ីចិញ្ចឹមកូនទៅថ្ងៃមុខ ។

រីឯទ្រព្យសម្បត្តិរួមមានតែផ្ទះចាស់មួយគ្រឿងកំពុងរស់នៅរាល់ថ្ងៃ ខ្លួនសុំសិទ្ធិគ្រប់គ្រង ។

ចំណែកឯបំណុលរួមជំពាក់ឈ្មោះ ហ ចំនួន ១៥០ដុល្លា "មួយរយហាសិបដុល្លា " ខ្លួនទទួលខុសត្រូវសងទាំងស្រុង ។

ចុងចម្លើយឈ្មោះ ស ស បានឆ្លើយថា ខ្លួនក៏យល់ព្រមលែងលះដើមចោទដែរ ដោយមូលហេតុបានរៀបការត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះមានកូន ០៥នាក់ តែការរស់នៅមិនចុះសំរុងនឹងគ្នា ដើមចោទមិនគោរពតាមកិច្ចសន្យា នៅតែលេងល្បែងស៊ីសងបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះអស់ ធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាមួយគ្នាតទៅទៀតបាន ទើបខ្លួនចុះចេញពីផ្ទះទៅរស់នៅជាមួយម្ដាយរបស់ខ្លួន បានរយះពេលតែ ០៣ខែប៉ុណ្ណោះ ថា ខ្លួនពុំដែលបានផ្ដល់ប្រាក់ចិញ្ចឹមកូនមែន ។

ចំពោះកូន ០៥នាក់ គឺកូនទី១ ឈ្មោះ ស ផល ភេទស្រី អាយុ ១០ឆ្នាំ, កូនទី២ ឈ្មោះ ស ផលឡ ភេទស្រី អាយុ ០៩ឆ្នាំ, កូនទី៣ ឈ្មោះ ស មរទ ភេទប្រុស អាយុ ០៨ឆ្នាំ, កូនទី៤ ឈ្មោះ ស សណ ភេទស្រី អាយុ ០៦ឆ្នាំ និង កូនទី៥ ឈ្មោះ ស ផល ភេទស្រី អាយុ ០៣ឆ្នាំ ខ្លួនសុខចិត្តប្រគល់អោយទៅប្រពន្ធគ្រប់គ្រងចុះ និង ជួយបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្ដាច់ចំនួន ១.២០០.០០០៛០០ "មួយលានពីរសែនរៀល" ដើម្បីជាដើមទុនទុកអោយដើមចោទរកស៊ីចិញ្ចឹមកូនទៅថ្ងៃមុខ ។

រីឯទ្រព្យសម្បត្តិរួមមានផែផ្ទះចាស់មួយគ្រឿងកំពុងរស់នៅរាល់ថ្ងៃ ខ្លួនសុខចិត្តប្រគល់ឱ្យទៅដើមចោទគ្រប់គ្រងជាកម្មសិទ្ធិចុះ ។

ចំណែកឯបំណុលរួមជំពាក់ឈ្មោះ ហ ចំនួន ១៥០ដុល្លា "មួយរយហាសិបដុល្លា " ខ្លួនមិនទទួលខុសត្រូវសងទេ ព្រោះដើមចោទធានាសងទាំងស្រុងអស់ហើយ ។

**តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា**

រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ដោយមានសភាពធ្ងន់ធ្ងរភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន

ដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

ទោះបីមានការលែងលះគ្នាក៏ដោយ ភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្តាយត្រូវមានកាតព្វកិច្ចអប់រំ ចិញ្ចឹមកូន តាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ និង ប្តឹងសុំ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

<u>តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ</u>

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>យល់ឃើញថា</u>

-ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានគ្នាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយបានព្រមព្រៀងដែរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចំពោះកូន ០៥នាក់ គឺកូនទី១ ឈ្មោះ ស ផល ភេទស្រី អាយុ ១០ឆ្នាំ. កូនទី២ ឈ្មោះ ស ផលឡ ភេទស្រី អាយុ ០៩ឆ្នាំ. កូនទី៣ ឈ្មោះ ស មះទ ភេទប្រុស អាយុ ០៨ឆ្នាំ. កូនទី៤ ឈ្មោះ ស សណា ភេទស្រី អាយុ ០៦ឆ្នាំ និង កូនទី៥ ឈ្មោះ ស ផល ភេទស្រី អាយុ ០៣ឆ្នាំ ដើមចោទសុំសិទ្ធិគ្រប់គ្រង ហើយចុងចម្លើយក៏យល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចុងចម្លើយសំណូមពរបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.២០០.០០០៛០០ " មួយលានពីរសែនរៀល " ដើម្បីជាដើមទុនទុកអោយដើមចោទរកស៊ីចិញ្ចឹមកូនទៅថ្ងៃមុខ ហើយដើមចោទក៏ព្រមព្រៀងដែរនោះ តុលាការនឹងសំរេចតាមការព្រមព្រៀងរបស់គូភាគី ។

-ទ្រព្យសម្បត្តិរួមមានផ្ទះចាស់មួយគ្រឿងកំពុងរស់នៅរាល់ថ្ងៃ ចុងចម្លើយសុខចិត្តប្រគល់អោយទៅដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ ហើយដើមចោទបានព្រមព្រៀងដែរនោះ តុលាការនឹងសំរេចតាមការព្រមព្រៀងគ្នារបស់គូភាគី ។

-បំណុលរួមជំពាក់ឈ្មោះ ហ ចំនួន ១៥០ដុល្លា " មួយរយហាសិបដុល្លា " ដើមចោទឈ្មោះ ះ ះទ សុខចិត្តទទួលខុសត្រូវសងតែម្នាក់ឯងនោះ តុលាការនឹងពិចារណាសំរេចទៅតាមការព្រមព្រៀងរបស់គូភាគី ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យអ្នកស្រី ៖ ៖ទ និង លោក ស ស លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-សំរេចឱ្យអ្នកស្រី ៖ ៖ទ ស្ថិតនៅភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០៥នាក់ គឺកូនទី១ ឈ្មោះ ស ផល ភេទស្រី អាយុ ១០ឆ្នាំ. កូនទី២ ឈ្មោះ ស ផលឡ ភេទស្រី អាយុ ០៩ឆ្នាំ. កូនទី៣ ឈ្មោះ ស មរទ ភេទប្រុស អាយុ ០៨ឆ្នាំ. កូនទី៤ ឈ្មោះ ស សណ ភេទស្រី អាយុ ០៦ឆ្នាំ និង កូនទី៥ ឈ្មោះ ស ផល ភេទស្រី អាយុ ០៣ឆ្នាំ ត្រូវប្រគល់អោយទៅដើមចោទឈ្មោះ ៖ ៖ទ គ្រប់គ្រង ។ ហើយបង្គាប់អោយចុងចម្លើយឈ្មោះ ស ស បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.២០០.០០០៛០០ "មួយលានពីរសែនរៀល" តាមការព្រមព្រៀងរបស់គូភាគី ។ មាតាបិតាត្រូវមានសិទ្ធិ និង ករណីយកិច្ចអប់រំ ថែរក្សា ចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខដល់កូនបាន ។

៦-ទ្រព្យសម្បត្តិរួមមានផែផ្ទះចាស់មួយគ្រឿងកំពុងរស់រាល់ថ្ងៃ ត្រូវប្រគល់អោយទៅឈ្មោះ ៖ ៖ទ គ្រប់គ្រងជាកម្មសិទ្ធិតាមការព្រមព្រៀងរបស់គូភាគី ។

៧-បំណុលរួមមានជំពាក់ឈ្មោះ ឃ ចំនួន ១៥០ដុល្លាជាបន្ទុករបស់ឈ្មោះ ៖ ៖ទ ទទួលខុសត្រូវសងតែម្នាក់ឯងតាមការព្រមព្រៀងរបស់គូភាគី ។

៨-សំរេចឱ្យចុងចម្លើយឈ្មោះ ស ស បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛០០ បូករួម ៧.០០០៛០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៧.០០០រៀលទៅដើមចោទវិញ ។

៩-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**

[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**

[redacted]